Disability Action Council

# Disability Today

Empowering & Enabling

DAC Newsletter Issue 001 May-June 2006

INSIDE THIS ISSUE


| | |
|---|---|
| A message from ED | 1 |
| Disability Sector News | 1 |
| Disability Legislation | 2 |
| Vocational training | 2 |
| Physical & Medical Rehab | 2 |
| Education hotline | 3 |
| Up Coming Events | 3 |
| Publications of interest | 3 |
| DAC Governing Board | 4 |
| DAC Secretariat | 4 |


**DISABILITY ACTION COUNCIL SECRETERIAT**

**#86, St.99, Sangkat Phsar Doeum Thkov, Khan Chamkar Mon, P.O. Box 115, Phnom Penh , Cambodia**

**Tel: (855-23)215 341**

**(855-23)218 797**

**E-mail: dac@dac.org.kh**

**http://www.dac.org.kh**

# A Message from the Executive Director

This is our first newsletter for sometime and we hope you will find it informative, and enjoyable. In it, we attempt to provide not only an insight into what is happening at DAC, but also in the Disability Sector in general. Please contact us if you have interesting news for future issues.



Global Campaign for Education, May 25, 2006

DAC has gone through a difficult period over the past two years, not only losing valuable members of staff, but also a degree of focus on key issues. It is my primary aim as the recently appointed Executive Director to address these concerns.

Importantly USAID has recently confirmed that it will continue to be our primary donor, for this we are most grateful. The reconstituted Board of DAC is providing effective leadership on policy development and we are working closely with government to make sure that the needs of the Disability Sector are represented at the highest level.

We are in the process of reviewing the 2005 - 2008 Strategic Plan and will produce a National Action Plan in the near future.

The first in a series of Member Information Days was recently held at the ABC centre. A range of topics were addressed and were well received. It is proposed to hold a further event in October.

DAC is about its members. We are committed to representing our membership both nationally and internationally. The primary task of DAC is to help facilitate and coordinate effective service delivery throughout the Disability Sector of Cambodia, please be assured that with your support we will be working hard to achieve this end.

# Disability Sector News

## Global Campaign for Education

DAC had a central involvement in the organization of the Global Campaign for Education – The theme/slogan adopted in Cambodia this year was Every Child Needs a Good Teacher.

## International Children Day

In partnership with CDPO and partners in the disability sector, DAC facilitated the involvement of children and young people in the day events. The aim of the event was to raise awareness of the rights and needs of children and young people with disabilities. Within the context of the national celebration of the international event.

## Disability Knowledge and Resource workshop (KaR)

Held on 24th May 2006 this one-day conference title "ARE DISABLED VOICES HEARD" was organized jointly by Cambodia Trust (CT), DAC and CDPO with support from DFID.

The conference brought together a range of national and international organization who work with disability. The conference recommended that persons with disabilities should be involved at all levels of management and policy development in all sectors.

## The New Chairman of BAC

Mr. Roger Lim, from Sterling Management Group, and Leong Hark Khim, from Vimean Seila Company Limited, were unanimously elected and re-elected Chairman and Vice Chair of BAC.

មានប្រែសំរួលជាភាសាខ្មែរនៅខាងក្នុង

## Evaluation of the Physical Rehabilitation Sector in Cambodia Report

The report (Evaluation of the Physical Rehabilitation Sector, PRS) which has recently been completed by a team of consultants commissioned by a steering group that comprised Cambodia Trust, Handicap International (Belgian French Sectors) The International Committee of the Red Cross, Veteran International, Cambodian Government- Ministry of Social Affairs, Veteran and Youth Rehabilitation and funded jointly by Ausaid and Unicef. The report aims to:

- Deliver a realistic picture of the physical rehab sector Cambodia
- Identify approach to the current institution management structures of the Sector; and
- Estimate the financial requirement of the sector and to prepare sustainable Financing options.

Some of the Key issues that the report highlights are:

The need for an effective and coordinated data collecting system across the sector.

The majority of the clients accessing PRCs (Physical Rehabilitation Centers) are ages 18 years or less, with road accident and disease and illness being of increase significance.

The lack effective quality control trough-out the PRCs affects the quality of services provided. INGOs are the principle service provider although there are some government and private serve providers.

The report explores alternative options for delivering physical rehabilitation services and debates the relative merits and difficulties associated with each. Assessment of these options is considered particularly important given the recent evidence to decrease in donor funding.

The options explored include a retaining the status quo, amalgamated management, government provision, contracting out and private sector led.

Based on the evidence the report recommends that contracting out of services and/or aspect of services be explored as a medium/long term option for the sector. In addition, in considerate of finance the report recommends the gradual introduction of a standard co-payment system with exemption granted to clearly defined group of clients to children, first time clients and to those accessing outreach services:

It was considerate that a payment–system would not only aid financial sustainability, but would also provide clients with a louder voice to demand service that met with their requirement.

NOTE: At the time of going to press the steering committee has commissioned an extension to the report, details of which are not available.

## Vocational Training for People with Disability

The Vocational Training, Income Generation and Job Placement Committee was formed to coordinating, supporting and improve the income generation of people with disability and their families and lead to more productive lives in communities through the quality of training skills and job provided.

The committee meet regularly and has developed the Quality Standard of Vocational Training Centre, identified the priority courses and preparing the training curriculum. All these out put will be well discuss to get accepted from all of the members in the workshop which will conducted on tentative schedule December 20-21, 2006. The next monthly meeting of VTC committee which will held on November 17, 2006, will detail discuss on how to operate the workshop . This also include the roles and responsibilities of all members or each organization.

Through the declaration of DAC to other relevant committees, some of the members/organizations get interest and suggest DAC invite them to attend in the next meeting of VTC and they also want to put their training curriculum to discuss in that the workshop too.

## Physical & Medical Rehab

- There are 5 main NGOs who run different Physical Rehabilitation Centers in Cambodia. Such as ICRC runs two regional centers Battambang, Kampong Speu and Orthopedic component factory, CT runs three centers Calmette, Kampong Chhnang and Sihanouk Ville, VI runs three centers Kean Kleang, Prey veng and Kratie, HI-B runs two centers Siem Reap and Takeo, HI-F runs two centers Spinal cord injury and Kampong cham. Other then these NGOs such as DDSP, CCMH, SPE or riziere aid a l'enfant, TASK, CARITAS. Some the above centers are finding an official recognition as different level such as regional or provincial from the MoSVY.
- In order to provide the service to patients of PwDs this section is in collaboration with specialize school like Cambodian School for Prothtist and Orthotist (CSPO) where can produce PO as in the region more than 10 PO per year and Technical School for Medical Care (TSMC)where can graduate up to this year is 198 Physiotherapists. In collaboration with TSMC, DAC has provided theory and practical course of about 60 hours for the third year PT student for each year. These human resources are essentially working in physical rehabilitation center and at community base rehabilitation.
- There are some NGOs who work with medical rehabilitation such as CIOMAL, ROSE charity, Center of Hope, Kunthabopha I & II, Angkor Children Hospital and Emergency Battambang. To answer to the needs of patient or disable people, physical and medical rehabilitation services are in a closed collaboration. Medical and co medical practitioners such as medical doctors, surgeons, midwifes, radiologists, labs, physiotherapists, POs, Occupational therapists, rehab workers, social workers are working closed together sequentially to support and maintain quality of life of patients and people with disabilities.
- In this recent year some POs and PTs are in the time of upgrading their knowledge according to fix to up date technical evolution today excluding their 3 years of basic knowledge and continuing education as short term of training.

PT upgrade for the first promotion is going to finish, this first promotion was under of coordinating by Ms.Claudie Ung for more than one year and who is now as a technical advisor of VI-C. The second promotion was done for the process of screening candidate and has continuing on providing the book of the first module for reading in advance,

**Any Disability Related News is welcome to be included in our Newsletter , Please submit your news to us**

# Education Hotline

DAC education staff Mr. Kong Vichetra and Ms. Sinead Quinn (Advisor) work at both strategic and grass roots level to provide educational opportunities for children and young people with disabilities.

Among the key tasks recently undertaken were:.

**Strategic Activity**

DAC project officer Mr. Kong Vichetra has recently been elected to the Board of NEP- NGO in Education Partnership. This organization has been chosen by MoEYS as its primary consultative body with the NGO sector with regard to education policy and reform. We consider this to represent an exciting opportunity to promote greater mainstreaming of disability issue in policy and practices of Government NGOs and Donors.

For the past year DAC has been one of 5 NEP Representatives to be invited to attend the Joint Technical Working Group in Education (JTWGE). Attendance at this joint Ministry, Donor, and NGOs group, that exists to oversea the development of education policy and reform. provides opportunity to influence Ministry/Donor Policy concerning education for children with disabilities and of other marginalized groups. Recently this has resulted in the formation of a working group specifically set up to address the needs of children and young people at greatest risk of marginalization and exclusion from the education- system. Core to the remit of this group will be more sustainability address the issue of disability in the education sector.

**Study Tour to Indonesia**

Ministry of Education staff supported by DAC Program Officer with financial support from UNISCO recently undertook a study tour to Indonesia. The tour focused on the experience evident in Indonesia in the field of Inclusive Education, Child Friendly Schools and Teacher Training.

**Voluntary Service Overseas (VSO) Mainstreaming Inclusive Education Project (MIE)**

This exciting new program will run for 4 years and will promote the mainstreaming of Inclusive Education in 6 provinces – Battambang, Banteay Meanchey, Kampot, Koh Kong, Rattanakiri and Mondolkiri. The project

# Disability Sector News (cont from page 1)

**The New Country Director of HI-F**

Mr.Yvon Thebaud was replaced by Mr.Emmanuel for a few months as Acting Country Director then now Ms.Lucile Papon is taking the post of country Director

**DAC Member Presentation Meetings -May o5 2006**

The first in a series of member information meeting was held at the ABC center. Amongst the subject areas addressed were the DAC/MoSVY service delivery strategies and detail of the variety of programs delivered by DAC. Board Member, Ms. Mary Scott and Mr. Ngin Saorath Delivered papers on aspects of DAC and CDPO activities.

**CMAA National Conference May 24 2006**

The Cambodia Mine Action and Victim Assistance Authority (CMAA) held its National Conference on Mine Action Achievement at the office of the Council on Minister. Organized by H.E Sam Sotha: Secretary General of CMAA and chaired by Deputy Prime Minister, H.E Sok An who also gave the keynotes address. The conference proved a greater success.

**New Staff Joining DAC**

Three new members of staff have recently joint DAC. There are Mr. Chan Sopheak Program Coordinator for Livelihood/VTC, Mr. Sopheak joined the secretariat from USG where he was Assistant Project Manager. Mrs. Oun Sotin volunteer program office, she joined DAC from ILO where she was a Garment Sector Monitor and Mr. Ham Hak Partnership and Communication Manager, who are joined DAC from his post as Information and Documentation Program Coordinator And Mr. James Clark VSO volunteer Education who is recently arrived from UK.

**Sinead and Chetra leave**

Two highly regarded DAC Secretariat colleagues have come to the end of their time at the secretariat in recent months. Ms. Sinead Quinn, VSO Special Needs Advisor and Mr. Kong Vichetra Program Officer Education, have both left a significant legacy. Both Sinead and Chetra have been very much valued colleagues at the DAC secretariat. We continue to wish them both every success and happiness in their next posts

**Publication of Interest**

- Water & Sanitation for disabled people and other vulnerable group-designing services to improve accessibility, Hazel Jones & Bob Reed©2005.
- Informed Choice Manual on Rural Household Latrine Selection-Ministry of Rural Development©2006

# Up Coming Events

- DAC have attended in the NGOs Forum monthly meeting and also a International Human Rights Day Dec. 10, 2006 Secretariat. The IHRD organizing committee is a group of representatives from civil society including NGOs, Union Federations and Rural Communities who are working together to organize the IHRD campaign and event which will be conducted from Dec. 01 to Dec. 10, 2006. As in the plan this even also include "Blue Kramar campaign" which are expected that at around 10,000 people attended.
- The opening ceremony of the Physical Rehabilitation Evaluation will be held in the Ministry of Social Affairs, Veterans and Youth Rehabilitation on July 03 2006

## (Continue from Page 2)

this first module is going to start on 3rd July 06 this second promotion will be attended by PT from different of those 5 main rehab NGOs about more then 10 PT in coordination of Ms.Edith van Wijngaarden Rehabilitation department coordinator of HI-B and Mr.Ung Sambath Program Officer of DAC. Closing for offering certificate to the first promotion and opening to the second promotion cere-

**Any Disability Related News is welcome to be included in our Newsletter , Please submit your news to us**

## សារមកពីនាយកប្រតិបត្តិ

នេះគឺជាព្រឹត្តប័ត្រលើកដំបូងរបស់យើងខ្ញុំ ហើយយើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងទទួលបាននូវព័ត៌មាន និងមានចិត្តរំភើប រីករាយចំពោះព្រឹត្តប័ត្រនេះជាមិនខានឡើយ ។ នៅក្នុងព្រឹត្តប័ត្រនេះ យើងខ្ញុំមានបំណងផ្តល់ជូន មិនត្រឹមតែជាចក្ខុវិស័យមួយ ដែលបង្ហាញពីអ្វីដែលកំពុងកើតឡើងចំពោះក្រុមប្រឹក្សាសកម្មភាពជនពិការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង បង្ហាញអំពីវិស័យពិការភាពទូទៅផងដែរ ។ សូមទំនាក់ទំនងមកយើងខ្ញុំ ប្រសិនបើលោកអ្នកមានព័ត៌មាន គួរអោយចាប់អារម្មណ៍ សំរាប់ការចេញផ្សាយលើកក្រោយ ។

ក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ កសព បានឆ្លងកាត់នូវការលំបាកជាច្រើនមិនត្រឹមតែបាត់បង់នូវបុគ្គលិកដ៏មានតំលៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបាត់បង់នូវកិរិតមួយ ក្នុងការផ្តោតយកចិត្តទុកដាក់ ទៅលើបញ្ហាសំខាន់ៗ ។ គោលដៅ ដ៏ចំបងរបស់យើងខ្ញុំ ក្នុងនាមជានាយកប្រតិបត្តិ ដែលទើបទទួលតំណែងថ្មីគឺជាការប្រឹងប្រែងដើម្បីដោះស្រាយ នូវកង្វល់ទាំងនេះ ។

រឿងសំខាន់មួយទៀតគឺថ្មីៗនេះ USAID បានបញ្ជាក់ថាខ្លួននឹងបន្តធ្វើជាម្ចាស់ជំនួយយ៉ាងសំខាន់ ចំពោះរឿងនេះ យើងសូមថ្លែងសេចក្តីអំណរគុណជាទីបំផុត ។ ក្រុមប្រឹក្សាភិបាលនៃ កសព ដែលត្រូវបានបង្កើតជាថ្មីឡើងវិញកំពុងផ្តល់នូវភាពដឹកនាំប្រកបដោយប្រសិទ្ធភាពលើការរៀបចំគោលនយោបាយហើយយើងខ្ញុំកំពុងធ្វើការ

យ៉ាងជិតស្និទ្ធ ជាមួយរដ្ឋាភិបាល ដើម្បីធ្វើអោយប្រាកដថា សេចក្តីត្រូវការនៃវិស័យពិការភាព ស្ថិតនៅក្នុងកិរិតមួយយ៉ាងខ្ពស់ ។

យើងកំពុងធ្វើការត្រួតពិនិត្យផែនការយុទ្ធសាស្រ្តឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ហើយនឹងរៀបចំធ្វើផែនការសកម្មភាពថ្នាក់ ជាតិ នាពេលខាងមុខឆាប់ៗនេះ ។

ទិវាចែករំលែកព័ត៌មានដល់សមាជិកលើកដំបូងរបស់យើងត្រូវបានប្រារព្ធធ្វើនៅ ABC Centre ។ ប្រធានបទយ៉ាង ច្រើនត្រូវបានលើកយកមកដោះស្រាយ និងបានទទួលយកយ៉ាងល្អ ។ គេបានស្នើសុំអោយប្រារព្ធធ្វើព្រឹត្តិការណ៍ បន្ថែមទៀត នៅក្នុងខែតុលា ។

កសព គឺជាកម្មសិទ្ធិរបស់សមាជិកខ្លួន ។ យើងប្តេជ្ញាចិត្តតំណាងដល់សមាជិកភាពរបស់យើង ទាំងកិរិតជាតិ និងអន្តរជាតិ ។

កិច្ចការដ៏សំខាន់របស់កសព គឺត្រូវជួយសម្របសម្រួលដល់ការចែកចាយសេវាប្រកបដោយប្រសិទ្ធភាព ក្នុងវិស័យ ពិការភាពទាំងមូល នៅក្នុងប្រទេសកម្ពុជា សូមបញ្ជាក់ថា ដោយមានការទទួលការគាំទ្រ ពីលោកអ្នក យើងខ្ញុំនឹងខិតខំ ប្រឹងប្រែងដើម្បីសំរេច នូវគោលដៅនេះ ។

## ព័ត៌មានស្តីអំពីវិស័យពិការភាព

### យុទ្ធនាការទូទៅសំរាប់ការអប់រំ

កសពបានធ្វើការចូលរួមយ៉ាងសំខាន់ ក្នុងការរៀបចំយុទ្ធនាការទូទៅសំរាប់ការអប់រំ- ប្រធានបទ/ពាក្យស្លោកបាន អនុម័តរួចហើយក្នុងប្រទេសកម្ពុជា នាឆ្នាំនេះគឺ *កុមារគ្រប់រូបត្រូវការគ្រូបង្រៀនដ៏ល្អ* ។

### ទិវាកុមារអន្តរជាតិ

ក្នុងភាពជាដៃគូជាមួយអង្គការ CPDO និងដៃគូដទៃទៀតក្នុង-វិស័យពិការភាព កសពបានជួយសម្រួល ដើម្បីឱ្យមាន ការចូលរួម-ពីសំណាក់កុមារ និងប្អូនតូចៗ នៅក្នុងទិវាព្រឹត្តិការណ៍នេះ ។ គោលដៅគឺដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិនិងសេចក្តីត្រូវការរបស់កុមារ និងកុមារពិការ ។ព្រឹត្តិការណ៍នេះផ្តល់នូវឱកាសយ៉ាងជាក់លាក់សំរាប់ កុមារប្អូនតូចៗនិងកុមារពិការ ដទៃទៀតដើម្បី ទាមទាពីសិទ្ធិរបស់ពួកគេ ។

### សិក្ខាសាលាស្តីអំពីចំណេះដឹង និងការស្រាវជ្រាវផ្នែកពិការភាព (KaR)

សន្និសីទរយៈពេលមួយថ្ងៃ ដែលបានប្រារព្ធធ្វើនៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៦ ក្រោមប្រធានបទមួយ "តើសំលេងរបស់ ជនពិការត្រូវបានគេស្តាប់លឺដែរឺទេ?" ត្រូវបានរៀបចំឡើង ដោយមានការ-ចូលរួមរៀបចំដោយអង្គការ កម្ពុជាត្រាស្ត (CT), DAC, និងអង្គការ CPDO និងបានឧបត្ថម្ភពីអង្គការ DFID ។ សន្និសីទនេះមានការចូលរួមពីសំណាក់អង្គការជាតិ និងអន្តរជាតិជាច្រើនដែលធ្វើការជាមួយវិស័យពិការភាព ។ អង្គសន្និសីទបានផ្តល់ជាអនុសាសន៍ថា ជនពិការគួរតែត្រូវបានចូលរួមក្នុងគ្រប់កិរិតគ្រប់គ្រង និងការអភិវឌ្ឍន៍គោលនយោបាយក្នុងគ្រប់វិស័យទាំងអស់ ។

### ប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ពាណិជ្ជកម្ម

លោក Roger Lim មកពីក្រុមគ្រប់គ្រងប្រាក់ស្នេរលើង និងលោក ឡឹង ហាក់គីម មកពីក្រុមហ៊ុនវិមានសីលា នីហរ័ណ អាហរ័ណ ត្រូវបានជ្រើសតាំងជាឯកច្ឆ័ន្ទ ធ្វើជាប្រធាន និងអនុប្រធានថ្មី នៃក្រុមប្រឹក្សាពិគ្រោះយោបល់ ផ្នែកពាណិជ្ជកម្ម ។

### នាយកក្នុងប្រទេសថ្មីនៃអង្គការជនពិការអន្តរជាតិបារាំង

លោក Emmanuel បានចូលជំនួសលោក Thebaud អស់រយៈពេលពីរបីខែហើយ ជានាយកស្តីទីក្នុងប្រទេស ចាប់ពីពេលនេះតទៅ។ អ្នកស្រី Lucile Papon ចូលកាន់មុខតំណែងជានាយិការក្នុងប្រទេស ។

### កិច្ចប្រជុំសមាជិកកសពថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦

កិច្ចប្រជុំព័ត៌មានលើកដំបូងស្តីអំពីសមាជិករបស់ខ្លួនទាំងអស់ត្រូវបានប្រារព្ធធ្វើនៅ ABC Center ។ ក្នុងចំណោមប្រធានបទ ទាំងអស់ដែលត្រូវលើកយកមក ដោះស្រាយគឺយុទ្ធសាស្រ្តសេវាចែក ចាយ របស់អង្គការ កសព/សអយ និងសេចក្តីពិស្តារនៃកម្មវិធីផ្សេងៗ ផ្តល់ជូនដោយកសព ។ សមាជិក

ក្រុមប្រឹក្សាភិបាល ដែលមានលោកស្រី ម៉ារី ស្កត់ និង លោក ងិន សៅរត្ន័ បានចែកជូននូវឯកសារមួយចំនួន ស្តីអំពីទិដ្ឋភាពនៃអង្គការកសព និងសកម្មភាពមួយ ចំនួនរបស់ អង្គការ CPDO ។

## សន្និសីទថ្នាក់ជាតិ **CMAA** ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៦

អាជ្ញាធរជួយសង្គ្រោះ និងសកម្មភាពកំចាត់មីនកម្ពុជា ហៅកាត់ (CMAA) បានប្រារព្ធធ្វើសន្និសីទជាតិរបស់ខ្លួន ស្តីអំពីសមិទ្ធិផលសកម្មភាពកំចាត់មីន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ អង្គសន្និសីទនេះបានរៀបចំឡើងដោយ ឯកឧត្តម សំ សុថា អគ្គលេខាធិការនៃអជ្ញាធរជួយសង្គ្រោះ និងសកម្មភាពកំចាត់មីនកម្ពុជា និងចូលរួមជាគណៈអធិបតីដោយ ឧបនាយករដ្ឋ មន្ត្រី សុខ អាន ដែលបានថ្លែងសុន្ទរកថា ប្រកបដោយអត្ថន័យជ្រាលជ្រៅ ។

## វេជ្ជបណ្ឌិត **Betsey Vanleit**

យើងមានសេចក្តីសោមនស្សណាស់ សូមជំរាបជូនថា លោកស្រី Betsey Vanleit បានមកដល់ទីក្រុងភ្នំពេញហើយ ។ វេជ្ជបណ្ឌិត Betsey Vanleit ដែលបំរើការនៅអង្គការជនពិការអន្តរជាតិបែលហ្សិក ត្រូវដឹកនាំគម្រោងក្នុងការ ប្រមូលព័ត៌មានសំខាន់ៗ ស្តីអំពីពិការភាពនៅក្នុងប្រទេស កម្ពុជា ។ គម្រោងនេះនឹងត្រូវបញ្ចប់ក្នុងរយៈពេល ១ឆ្នាំ ហើយ ត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលប៊ែលហ្សិក ។ សំរាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅកាន់លេខ (៨៥៥-២៣) ២១៧ ២៩៨ ។

## **Liz និង Kathy** បានបញ្ចប់បេសកកម្មការងារ

សហសេវិកនៃលេខាធិការដ្ឋានកសព ដ៏ឧត្តុងឧត្តមបំផុត ចំនួនពីររូប បានបញ្ចប់អណត្តិរបស់ខ្លួននៅលេខាធិការដ្ឋាន ក្នុង រយៈពេលប៉ុន្មានខែថ្មីៗនេះ ។ Kathy Kremer ជាទីប្រឹក្សាផ្នែកសេចក្តីត្រូវការអប់រំពិសេស និង Liz Cross ជាសហសេវិក CBM និងជាមន្ត្រីគម្រោងកសព អ្នកទាំងពីរបានបន្សល់នូវមរតិកដ៏មានតម្លៃ ។ ទាំងអ្នកស្រី Kathy និងអ្នកស្រី Liz

បានធ្វើជា សហសេវិកដ៏មានតម្លៃបំផុត នៅឯលេខាធិការដ្ឋានកសព ។ យើងសូមជូនពរ ដល់អ្នកស្រីទាំងពីរនាក់សូមទទួលបាននូវជោគជ័យ និងសុភមង្គលនៅក្នុងមុខតំណែងក្រោយៗ ។

## សិក្ខាសាលាស្តីអំពីពិការភាព និងការអភិវឌ្ឍន៍

សិក្ខាសាលាត្រូវបានរៀបចំធ្វើនៅក្នុងខេត្តព្រៃវែង នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ដែលបានរៀបចំឡើងតាមរយៈ គម្រោង ADI នៃគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាសហការជាមួយអង្គការអតីតយុទ្ធជនអន្តរជាតិ ។

## ច្បាប់ស្តីអំពីសិទ្ធិជនពិការ តើយើងនឹងទទួលបានអ្វីខ្លះ?

អត្ថប្រយោជន៍ដ៏មានសក្តានុពល ក្នុងការអនុម័ត និងការអនុវត្តន៍ច្បាប់ស្តីអំពីពិការភាពរួមមានដូចជា:

*ចំពោះជាតិ:*

- បំពេញកាតព្វកិច្ចដើម្បីអនុវត្តតាមសេចក្តីប្រកាសលក្ខណៈអន្តរជាតិ/តំបន់
- លើកកំពស់ការទំនាក់ទំនងជាមួយបណ្តាប្រទេសអាស៊ាន ដើម្បីធ្វើការប្រៀបធៀបពី ច្បាប់ស្តីអំពីពិការភាព ។
- កាត់បន្ថយការចំណាយថវិការជាតិលើការថែទាំជនពិការ និងផ្សព្វផ្សាយពីសកម្មភាពនានាផ្នែកសេដ្ឋកិច្ចដែលទាក់ទងដល់ជនពិការ
- ពង្រឹកសុខុមាលភាពសង្គមនិងរក្សាតំលៃប្រពៃណី និងវប្បធម៌ជាតិ ។

*ចំពោះរដ្ឋាភិបាល:*

- ជំរុញនូវការអនុវត្តន៍នៃគោលនយោបាយរបស់រដ្ឋាភិបាល ស្តីអំពីការកាត់បន្ថយភាពក្រីក្រ ។
- ការបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវច្បាស់លាស់ រវាងរយៈបណ្តោយក្រសួង ដើម្បីដោះស្រាយបញ្ហា ពិការភាព ។
- បង្កការងាយស្រួលក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតំលៃលើការអនុវត្តន៍ច្បាប់ និងការអនុវត្តន៍តាម គោលនយោបាយរបស់រដ្ឋាភិបាល ។

*ចំពោះសង្គម:*

- លើកកំពស់ការយល់ដឹងអំពីពិការភាពនិងការពារដល់ជនពិការ
- កាត់បន្ថយការរើសអើង និងជំរុញនូវការបញ្ចូលជនពិការ ទៅក្នុងសហគមន៍
- សំរាលបន្ទុកលើការថែទាំ និងការឧបត្ថម្ភដល់ជនពិការ ។

*ចំពោះស្ថាប័នឯកជន:*

- ការលើកទឹកចិត្តផ្នែកវិនិយោគ ការដកពន្ធ និងជ្រើសរើសយកនិយោជិត ដែលប្រកបដោយគុណភាព និងសមត្ថភាព
- រួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម តាមរយៈការស្រូប យកនូវផលិតភាពដ៏មានសក្តានុពល ពីជនពិការ
- ជំរុញនូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សំរាប់ជនពិការ

DAC Empowers & Enables

*<u>អត្ថប្រយោជន៍ចំពោះជនពិការ:</u>*

- មានទំនុកចិត្តចំពោះសមត្ថភាពនិងលទ្ធភាពផ្ទាល់ខ្លួនហើយ ទទួលបាន នូវការលើកទឹកចិត្ត និងការគាំទ្រ
- ប្រើប្រាស់សក្តានុពលដែលនៅសល់ដើម្បីរួមចំណែកដល់ការ អភិវឌ្ឍន៍ សេដ្ឋកិច្ចសង្គម
- ទទួលបាននូវសេវាគុណភាព និងបរិមាណ
- សិទ្ធិនិងផលប្រយោជន៍ត្រូវបានការពារយ៉ាងស្របច្បាប់ មានសមភាព និងយុត្តិធម៌ក្នុងសង្គម រវាងជនពិការ និងប្រជាពលរដ្ឋដទៃទៀតក្នុងសង្គម ។

<u>ច្បាប់ជួយដល់ជនពិការមានការរីកចំរើន</u>

ឯកឧត្តម អ៊ឹង ទាស៊ាម រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិ សម្បទាមានប្រសាសន៍ថា "ខ្ញុំនៅតែ សង្ឃឹមថា សេចក្តីព្រៀងច្បាប់នេះ នឹងត្រូវបានអនុម័តរួចក្នុង ឆ្នាំនេះ ។ គាត់មានប្រសាសន៍ទៀតថា សេចក្តីព្រៀងច្បាប់នេះ បានពិនិត្យមើល ពីរដងរួចមកហើយ ដោយក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី ហើយឥឡូវនេះរង់ចាំការពិនិត្យមើលពី អន្តរក្រសួង មុនពេលសភាជាតិអាចបោះ ឆ្នោត អនុម័តលើច្បាប់នេះ ។

ដក់ស្រង់ពីការសែត Cambodia Daily មេសា 2006

## <u>ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ</u>

សព្វថ្ងៃនេះ មានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៩ ដែលកំពុងផ្តល់សេវាដល់ជនពិការ មណ្ឌលទាំងនោះ រួមមានដូចជា: មណ្ឌលចំនួន ៣ ក្នុងក្រុងភ្នំពេញ ១ នៅខេត្តកណ្តាល ១ នៅខេត្តបាត់ដំបង ១ នៅខេត្តពោធិសាត់ ១ នៅខេត្តបន្ទាយមានជ័យ និងមណ្ឌលមួយទៀតមាននៅខេត្តក្រចេះ។ មុខវិជ្ជាប្លែកៗគ្នាជាច្រើន ដែលត្រូវបានដាក់សំរាប់ការបណ្តុះបណ្តាល នៅក្នុងចំណោមមណ្ឌលទាំងនោះ រួមមាន: ការចិញ្ចឹមត្រី ការចិញ្ចឹមសត្វ ( ដូចជា: គោ ជ្រូក មាន់ ទា ការបង្កាត់ពូជសត្វ ឬការចិញ្ចឹមសត្វ ជាដើម ) ការថែគ្រឿងសង្ហារឹម ការកាត់ដេរ សំលៀកបំពាក់ ការផលិតស្បែកជើង ចំលាក់ រូបសំណាក ( ចំលាក់ធ្វើអំពីឈើ ) ចំលាក់ធ្វើអំពី ស្បែក ការផលិត សំភារៈធ្វើអំពីផ្តៅ ឫស្សី ត្រឡោកដូង ការដាំដុះ (ដូចជា: កន្លែងបណ្តុះកូនឈើ បណ្តុះ ផ្សិត និងបន្លែ ជាដើម ) ការត្បាញក្រមាហូល ផាមួង ក្រណាត់ កន្ទេល ការធ្វើម្ហូប និងក្រឡុកផ្លែឈើ ជាង-ជួលជុលមេសោរ និងកូន សោរ ជំនាញខាងចុងភៅ ជំនាញខាងភ្លេងប្រពៃណីខ្មែរបុរាណ ការផលិតគ្រឿងអលង្ការធ្វើអំពីប្រាក់ ជាងមាស ការផលិត សំភារៈធ្វើអំពីស័ង្កសី កាត់ដេរសំលៀកបំពាក់( ខាងកាត់ដេរ) ម៉ាស៊ីនត្រជាក់ ជាងកាត់សក់ ជាងតុបតែងសក់ ជាងដែក ជាងផ្សា កម្មករដែកបន្ទះ ជាងភ្លើង ជាង-បញ្ចូលអាគុយ ជំនាញកុំព្យូរទ័រនិងជួសជុល ជាងជួសជុល វិទ្យុ វីស៊ីឌី ឌីវីឌី ទូរទស្សន៍ ជាងជួសជុលយានយន្ត ជាងជួសជុលម៉ូតូ និងជាងជួសជុលអណ្តូងស្នប់ ។

គណៈកម្មការ VT/JP/IG ជួបប្រជុំគ្នាជាទៀតទាត់ ដើម្បីអភិវឌ្ឍ បទដ្ឋានគុណភាពរបស់មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើការចែករំលែកនូវការងារជោគជ័យទៅវិញទៅមក ។

## <u>ព័ត៌មានស្តីពីការអប់រំ</u>

លោក គង់ វិចិត្រា និង កញ្ញា Sinead Quinn បុគ្គលិកផ្នែកអប់រំ របស់ កសព បានធ្វើការទាំងកំរិតយុទ្ធសាស្ត្រ និងកំរិតមូលដ្ឋានដើម្បីផ្តល់ឱកាសនៃការសិក្សាសំរាប់កុមារ និងយុវជនពិការ, ក្នុងចំនោមនោះកិច្ចការសំខាន់ៗដែលបានធ្វើរួមមាន:

<u>សកម្មភាពយុទ្ធសាស្ត្រ</u>

នាពេលថ្មីៗនេះ លោក គង់ វិចិត្រា មន្ត្រីកម្មវិធី កសព ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាល របស់ NEP ជាអង្គការដៃគូរ ផ្នែកអប់រំ។ អង្គការនេះត្រូវបានក្រសួងអប់រំ ជ្រើសរើសជាស្ថាប័ណប្រឹក្សាយោបល់លើគោលនយោបាយនិងកំណែទំរង់ផ្នែកអប់រំ។ យើងគឹតថានេះជាឱកាស ដ៏ធំធេងក្នុងការជំរុញការបញ្ជ្រាបបញ្ហាពិការភាព ទៅក្នុងគោលនយោបាយ និង-ការអនុវត្តរបស់រដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយ។ សំរាប់ឆ្នាំកន្លងទៅ កសព បានក្លាយ ជាតំណាងមួយក្នុងចំណោមអ្នកតំណាងប្រាំ របស់ NEP ដែលត្រូវបានអញ្ជើញអោយចូលរួមក្នុង ក្រុមការងារបច្ចេកទេសផ្នែកអបរំ (JTWGE) ដែលមានការចូលរួមពីក្រសួង ម្ចាស់ជំនួយក្រុមអង្គការក្រៅរដ្ឋាភិបាល ដើម្បីពិនិត្យ តាមដានមើលការរីកចំរើន-លើគោលនយោបាយ និង ការកែទំរង់ផ្នែកអប់រំ។ នេះបានផ្តល់ឱកាសក្នុងការធ្វើ អោយមានឥទ្ធិពលលើគោលនយោបាយរបស់ក្រសួង និងម្ចាស់ជំនួយដែលពាក់ពន្ធ័ការអប់រំ សំរាប់កុមារពិការ ហើយនិងក្រុមដែលងាយរងគ្រោះដ៏ទៃទៀត។ លទ្ធផល-នាពេលថ្មីៗនេះគឺការបង្កើត នូវក្រុមការងារដែលធ្វើការដើម្បីដោះស្រាយនូវតំរូវការរបស់កុមារ និង យុវជនដែលមាន-ហានិភ័យខ្ពស់ ហើយដែលត្រូវបានគេកាត់ចេញពិប្រពន្ធ័អប់រំ។

## ទស្សនៈកិច្ចសិក្សានៅ ប្រទេស **Indonesia**

បុគ្គលិកក្រសួងអប់រំដែលគាំទ្រដោយមន្ត្រីកម្មវិធីកសព និងមានការគាំទ្រផ្នែកហិរញ្ញវត្ថុពី UNISCO និងទៅធ្វើទស្សនៈកិច្ចសិក្សានៅ Indonesia. ទស្សនៈកិច្ចសិក្សានេះ ផ្តោតលើការបង្ហាញបទពិសោធន៏របស់Indonesia.លើវិស័យអប់រំបញ្ចូលគ្នា និង សាលាកុមារមេត្រី រួមទាំងការបណ្តុះបណ្តាលដល់គ្រូផងដែរ ។

## គំរោងការបញ្រ្ជៀបអប់រំបញ្ចូលគ្នា (VSO)

គំរោងដ៏គួរអោយចាប់អារម្មណ៏នេះ និងដំណើរការរយៈពេល ៤ឆ្នាំ ដែលនិងជំរុញបញ្រ្ជៀបការអប់រំបញ្ចូលគ្នាក្នុង ៦ខេត្ត គឺ បាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តកំពត, ខេត្តកោះកុង, ខេត្តរតនៈគីរី និង ខេត្តមណ្ឌលគីរី ។ មកទល់ពេលនេះ កសព បានគាំទ្រគំរោងក្នុងទំរងជាការបណ្តុះបណ្តាលផ្សព្វផ្សាយ ការយល់ដឹងអំពីពិការភាពទាំងថ្នាក់ខេត្ត និង ទីតាំងកណ្តាល ។

## **ការស្តារលទ្ធភាពពលកម្ម កាយសម្បទា និងវេជ្ជសាស្ត្រ**

អង្គការមិនមែនរដ្ឋាភិបាលធំៗចំនួនប្រាំ ដែលរៀបចំចាត់ចែងមណ្ឌលស្តារលទ្ធភាពពលកម្មនៅកម្ពុជា ។គណៈកម្មការកាកបាទក្រហមអន្តរជាតិ (ICRC) ធ្វើការរៀបចំ ចាត់ចែងមជ្ឈមណ្ឌល ភូមិភាគចំនួន ពីរគឺ នៅបាត់ដំបង និងកំពង់ស្ពឺ និងរោងចក្រ ផលិតឧបករណ៏រណប ។ អង្គការ Cambodia Trust ធ្វើការរៀបចំចាត់ចែង មជ្ឈមណ្ឌលបី គឺនៅមន្ទីរពេទ្យកាល់ម៉ែត កំពង់ឆ្នាំង និងនៅក្រុងព្រះសីហនុ ។ VI ធ្វើការរៀបចំចាត់ចែង មជ្ឈមណ្ឌលចំនួនបីគឺ នៅ គៀនឃ្លាំង ព្រៃវែង និងក្រចេះ ។ HIB ធ្វើការរៀបចំ ចាត់ចែងមជ្ឈមណ្ឌលចំនួនពីរ គឺនៅសៀមរាប និងតាកែវ និង HIF ធ្វើការរៀបចំចាត់ចែង មជ្ឈមណ្ឌលចំនួនពីរគឺ នៅមជ្ឈមណ្ឌលរបួសខួរឆ្អឹងខ្នង និងមណ្ឌលស្តារនៅកំពង់ចាម ។

ក្រៅពីនេះ មានអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀតដូចជា DDSP, CCMH, SPE, Task និង CARITAS បានធ្វើការរៀបចំចាត់ចែង គំរោងស្តារលទ្ធភាពពលកម្ម សហគមន៏ជាច្រើន ទោះជាអង្គការទាំងនេះ មិនទាន់មានសេចក្តី ប្រកាសទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាលក៏ដោយ ។

DACផ្នែកស្តារលទ្ធភាពពលកម្ម និងកាយសម្បទាតែងតែផ្តល់នូវសេវាយ៉ាងមានប្រសិទ្ធភាព សំរាប់ជនពិការ ដោយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយ សាលាជំនាញឯកទេសជាច្រើនដូចជាសាលា P&O កម្ពុជា (CSPO) ដែលមកទល់ពេលនេះមានអ្នកបញ្ចប់ការសិក្សាចំនួន ១៥0នាក់ហើយ និងមួយទៀតគឺសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ (TSMC) ដែលបានបណ្តុះបណ្តាលនិស្សិតផ្នែកព្យាបាលដោយចលនា ចំនួន ១៩៨នាក់ហើយ មកទល់ពេលនេះ ។

DAC បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ TSMC ហើយបានផ្តល់ការបង្រៀនចំនួន ៦0ម៉ោង ដល់និស្សិតឆ្នាំទីបី ។

អង្គការមិនមែនរដ្ឋាភិបាលនានាដូចជា CIOMAL អង្គការសប្បុរសធម៌ ROSE កម្ពុជា មជ្ឈមណ្ឌលនៃក្តីសង្ឃឹម មន្ទីរពេទ្យគន្ធបុប្ផាទីមួយ និងទីពីរ ដែលជាមន្ទីរពេទ្យ និងជាផ្នែកសង្គ្រោះបន្ទាន់កុមារអង្គរ នៅបាត់ដំបង បានធ្វើការផ្នែកស្តារវេជ្ជសាស្ត្រ ។ អង្គការទាំងនេះ បានជួយ សម្របសម្រួល និងផ្តល់នូវសេវាផ្គត់ផ្គង់ទាក់ទងនឹង ផ្នែកវេជ្ជសាស្ត្រ និង បុគ្គលិកអមហវេជ្ជសាស្ត្រ ដើម្បីជួយផ្តល់នូវសេវាស្តារ ដល់អ្នកជំងឺ និងជនពិការអោយមានប្រសិទ្ធភាព ។

វគ្គបំពាក់បំប៉នអ្នកព្យាបាលដោយចលនាជំនាន់ទីមួយ នឹងត្រូវបិទនៅក្នុងខែកក្កដា ។ វគ្គបំពាក់បំប៉ននេះ ត្រូវបាន សំរបំរួលដោយអ្នកស្រី Claudie Ung កាលពីឆ្នាំកន្លងទៅ ដែលអ្នកស្រីបានធ្វើការជាទីប្រឹក្សាបច្ចេកទេស ។ ជំនាន់២ បាននិងកំពុងដំនើរការ ។

មេរៀនដំបូង នឹងត្រូវចាប់ផ្តើមឡើងនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២00៦ ។ វគ្គនេះនឹងត្រូវបានចូលរួមដោយ អ្នកព្យាបាលដោយចលនា ដែលមកពីអង្គការស្តារលទ្ធភាពពលកម្មធំៗចំនួនបី ដែលសរុបមានប្រហែល ១៣នាក់ ។ ការប្រារព្ធពិធីបើកវគ្គ សិក្សាសំរាប់ជំនាន់ទី២នឹងត្រូវធ្វើឡើងនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២00៦ ។

ឥឡូវនេះ ក្រុមការងារដែលធ្វើការផ្នែករទេះជនពិការ បាននិងកំពុងជួបប្រជុំ គ្នាយ៉ាងទៀងទាត់ដោយមានការចូលរួមពីសំណាក់ ក្រសួង ស.អ.យ DAC, AAR-J, NCDP, JS-C, HI-B និង ICRC ។

**ព័តិមានស្តីពីពិការភាពទាំងឡាយត្រូវបានស្វាគមន៏អោយដាក់បញ្ចូលក្នុងព្រឹត្តិបត្រ័នេះ, សូមទាក់ទងមកយើងខ្ញុំ,,**

# DISABILITY ACTION COUNCIL

## DAC Governing Board

1. **Mr. Ngin Saorath**: Chairperson and Executive Director of CDPO
2. **Mr. Touch Samon**: Deputy Chairperson and Deputy Director General of Social Welfare of MoSVY
3. **Ms. Mary S**cott: Country Director of Cambodia Trust
4. **Ms. Edith van Wijn**gaarden: Coordinator of Rehab Department of HI-B
5. **Mr. Kuon P**heng: Director of Victim Assistance Department/CMAA
6. **Mr. Boun Mao**: Executive Director of ABC.
7. **Mr. Debashish S**ANYAL: Finance/ Admin Manager of TOTAL Cambodge
8. **Dr. Prak Piseth Raingsey**: Director-Preventive Medicine Department of MoH
9. **Ms. Sieng Sorvathanna**: Director, Early Childhood Education Department of MoEYS

## DAC Secretariat:

1. **Mr. Long Sothy-Executive Director**
2. **Mr. Brian Thomos -Management Adviser**
3. **Ms. Ren Ranaroth-Finance and Admin Manager**
4. **Rev. Charlie Dittmeier – Deaf Project**
5. **Ms. Sinead Quinn – Special Education advisor**
6. **Mr. Kong Vichetra– P O for Education and Children with disability**
7. **Mr. Ung Sambath- P O for Rehabilitation**
8. **Mr. Vorn Samphors-P O for Legislation and Livelihood**
9. **Ms. Vath Samnang-Office Manager**
10. **Ms. Nou Vuoch Hun-Cashier/Assistant Administrator**
11. **Mr. Srey Chan-IT/Website Administrator**
12. **Mr. Ang Narith-Librarian, Networking Administrator**
13. **Mr. Chhem Vuthy-Driver/ Messenger**
14. **Mr. Pring Pech-Procurement Officer/Driver**
15. **Ms. Pring Ryna-Cleaner**
16. **Mr. Yung Korop-Day Guard**

# DAC Secretariat



Left to Right (Standing) : Mr. Chhem Vuthy,Mr. Srey Chan, Ms. Pring Ryna,Ms. Sinead Quinn, Ms. Nou Vuoch Hun,

Ms. Vath Samnang, Ms. Ren Ranaroth, Mr. Vorn Samphors, Mr. Brian Thomos, Mr. Long Sothy ,

Left to Right (Sitting) : Mr. Yung Korop, Mr. Pring Pech, Mr. Kong Vichetra, Mr. Ung Sambath, Mr. Ang Narith